សួស្តី នៅក្នុងរូបភាពនេះ គឺយើងនឹងនិយាយអំពីការជិះយន្តហោះ
អញ្ចឹងជាទូទៅការធ្វើដំណើររបស់មនុស្សយើងម្នាក់ៗ នៅគ្រប់ប្រទេសទាំងអស់
យើងតែងតែមានមធ្យោបាយធ្វើដំណើរចំនួនបី ពីរ[...] បីប្រភេទ
ដែលយើងឃើញមធ្យោបាយធ្វើដំណើរទីមួយ គឺការធ្វើដំណើរតាមផ្លូវគោក
អញ្ចឹងការធ្វើដំណើរតាមផ្លូវគោកមានដូចជាការធ្វើដំណើរតាមផ្លូវថ្នល់ ការធ្វើដំណើរតាមផ្លូវជាតិ
និងការធ្វើដំណើរតាមផ្លូវដែកជាដើម អញ្ចឹងគេហៅថាការធ្វើដំណើរតាមផ្លូវគោក
ចំណែកឯមួយទៀតគឺការធ្វើដំណើរតាមផ្លូវទឹក ដែលយើងប្រើប្រាស់កប៉ាល់ ប្រើប្រាស់នាវា
ឬក៏ប្រើប្រាស់ទូកជាដើមដើម្បីធ្វើដំណើរ អញ្ចឹងតាមផ្លូវទឹកយើងប្រើប្រាស់ទូក ឬក៏កប៉ាល់
យើងហៅថាទូក អញ្ចឹងមួយទៀតគឺការធ្វើដំណើរតាមផ្លូវអាកាស ដោយសារតែបច្ចេកវិជ្ជាជឿនលឿន
ដូច្នេះយើងអាចធ្វើដំណើរតាមផ្លូវអាកាសបាន ដោយយើងប្រើប្រាស់ជាយន្តហោះ
អញ្ចឹងអ្នកខ្លះគាត់ប្រើប្រាស់យន្តហោះ ហើយនិងអ្នកខ្លះទៀតគាត់ប្រើ
គាត់ធ្វើដំណើរតាមរយៈឧទ្ធម្ភាគចក្រ អញ្ចឹងវាមានពីរប្រភេទដើម្បីធ្វើដំណើរតាមផ្លូវអាកាស
ដោយប្រើឧទ្ធម្ភាគចក្រ ឬក៏ប្រើប្រាស់យន្តហោះ ដែលជាក់ស្តែងនៅក្នុងរូបភាពនេះ
គឺយើងនឹងនិយាយអំពីការធ្វើដំណើរតាមផ្លូវអាកាស គឺការប្រើប្រាស់យន្តហោះ

ដោយយើងមើលមកក្នុងរូបភាពទី ១ នៅក្នុងរូបភាពទី ១ យើងឃើញមានបុរសម្នាក់
គាត់កំពុងតែគេងហាលថ្ងៃនៅលើពៅអ៊ីមួយ អញ្ចឹងបុរសម្នាក់នោះ
គាត់ប្រហែលជាអង្គុយនៅមាត់សមុទ្រ ដែលវាអាចជាថ្ងៃវិស្សមកាលរបស់គាត់
អញ្ចឹងបានន័យថាគាត់អត់ធ្វើការទេ អញ្ចឹងថ្ងៃវិស្សមកាលរបស់គាត់ គឺគាត់ដើរមកលេងសមុទ្រ
ឬក៏គាត់បានមកលេងនូវសមុទ្រ ឬក៏នៅមាត់សមុទ្រ ដោយគាត់អង្គុយនៅលើពៅអ៊ីនៅឆ្នេរសមុទ្រ
ដោយអង្គុយហាលថ្ងៃ ហើយពាក់វ៉ែនតាខ្មៅ អញ្ចឹងយើងឃើញគាត់អង្គុយលើពៅអ៊ី
ដែលពៅអ៊ីរបស់គាត់គឺមានជើងចំនួនពីរ ហើយគាត់អង្គុយផ្អែកទៅលើបង្អែកពៅអ៊ី
បានន័យថាគាត់អង្គុយទម្រេតខ្លួនទៅលើបង្អែកនៃពៅអ៊ី
ហើយជើងទាំងពីររបស់គាត់ដាក់នៅលើពៅអ៊ី អញ្ចឹងគាត់កំពុងតែគេង ដោយពាក់វ៉ែនតាខ្មៅ
ឬក៏ពាក់អាវសដៃខ្លី និងខោជើងខ្លីពណ៌សដែរ
ដែលជាសម្លៀកបំពាក់សម្រាប់ការធ្វើដំណើរតាមសមុទ្រ ឬក៏ការធ្វើដំណើរតាមមាត់សមុទ្រ
អញ្ចឹងគាត់កាន់ដូងមួយផ្លែ គាត់កាន់ផ្លែដូង ដែលយើងឃើញនៅក្នុងផ្លែដូង
គឺមានចោះក្បាលរួចរាល់ហើយ បានន័យថាគេកាប់ក្បាលផ្លែដូងរួចហើយ ដើម្បីដាក់ញ៉ាំទឹក
អញ្ចឹងយើងឃើញនៅក្នុងផ្លែដូង នៅក្នុងផ្លែដូងដែលគាត់កំពុងកាន់ ផ្លែដូងមានពណ៌បៃតងហ្នឹង
គឺគាត់មានដាក់បំពង់បឺតមួយ ឬក៏ទុយោមួយ

Copyright © 2016 www.aakanee.com – This document and the corresponding illustration and recording are provided under a Creative Commons Attribution-NonCommercial-ShareAlike 4.0 International License.

ដោយសារតែផ្លែដូងគឺយើងញ៉ាំទឹកវា ដូច្នេះយើងត្រូវបឺតទឹកចេញពីក្នុងផ្លែដូង ដែលជាទូទៅផ្លែដូងគឺ
ទឹករបស់វាមានរសជាតិប្រៃបន្តិច ហើយនិងផ្អែម អញ្ចឹងបានន័យថាប្រៃផ្អែមៗ
វាមានរសជាតិប្រៃបន្តិច ប៉ុន្តែផ្លែដូងគឺឆ្ងាញ់ ហើយវាអាចធ្វើឲ្យយើងបាត់ស្រេកទឹកបាន
ជាពិសេសនៅពេលដែលយើងទៅលេងមាត់សមុទ្រ នៅពេលដែលយើងញ៉ាំផ្លែដូង
គឺមានអារម្មណ៍ថាស្រស់ស្រាយ ដែលយើងឃើញផ្លែដូងគឺ ពេលខ្លះគឺយើងអាចញ៉ាំសាច់បានផងដែរ
ដោយពេលដែលផ្លែដូងខ្ចី ដូងខ្ចីគឺយើងញ៉ាំទឹកផង បន្ទាប់ពីញ៉ាំទឹក យើងញ៉ាំសាច់ទៀត
ដោយយើងគ្រាន់តែពុះសំបកវាចេញ នោះយើងអាចញ៉ាំសាច់បានដោយប្រើស្លាបព្រា
ដោយប្រើស្លាបព្រា ដើម្បីកោសសាច់វា អញ្ចឹងយើងអាចកោសសាច់ដូងញ៉ាំបាន នៅពេលដែលដូងខ្ចី
ដោយតែសំបករបស់វា គឺយើងអត់ញ៉ាំទេ បានន័យថាសំបករបស់វាគឺរឹង
ហើយផ្លែដូងគឺមានលលាដ៍ទៀត អញ្ចឹងលលាដ៍វារឹងជាងសំបក ដូច្នេះយើងអត់ញ៉ាំទេ
យើងញ៉ាំតែសាច់ដូងពណ៌ស យើងញ៉ាំតែសាច់ដូងពណ៌សប៉ុណ្ណោះ ដោយសំបក សំបកដូង
និងលលាដ៍ដូង លលាដ៍ដូងគឺយើងអត់យកទេ គឺយើងបោះចោល អញ្ចឹងនៅក្នុងរូបភាពនេះ
គឺគាត់កំពុងតែអង្គុយញ៉ាំផ្លែដូង ឬក៏ញ៉ាំទឹកដូង ដោយអង្គុយលើពៅអ៊ី ហើយហាលថ្ងៃនៅមាត់សមុទ្រ
ដោយយើងឃើញនៅខាងក្រោយពៅអ៊ី នៅខាងក្រោយពៅអ៊ីរបស់គាត់ គឺជាដើមដូងមួយដើម
អញ្ចឹងផ្លែដូងគឺជាផ្លែរបស់ដើមដូង ដែលនៅខាងក្រោយគាត់គឺជាដើមដូង ដែលដើមដូងគឺមានធាង
យើងហៅថាធាង យើងអត់ហៅថាមែកទេ ដោយសារដើមដូងអត់មានមែក[ទេ] ដូច្នេះវាមានធាង
ធាងរបស់វាគឺបែកចេញជាស្លឹក អញ្ចឹងស្លឹករបស់វាគឺដុះនៅនឹងធាង
ហើយយើងឃើញមានផ្លែដូចជាច្រើនកំពុងតែនៅលើដើម
អញ្ចឹងបានន័យថានៅពេលដែលផ្លែដូងនោះល្មម បានន័យថាវាចាស់ល្មមសម្រាប់ញ៉ាំ
គេនឹងឡើងបេះផ្លែដូងនោះយកមកញ៉ាំ ដោយផ្លែដូងគឺដុះ ផ្លែវាជាចង្កោមៗច្រើន។

បន្ទាប់មកទៀតរូបភាពទី ២ នៅក្នុងរូបភាពទី ២ យើងឃើញបុរសម្នាក់នោះ
បន្ទាប់ពីគាត់បញ្ចប់ការវិស្សមកាលរបស់គាត់នៅមាត់សមុទ្រហើយ អញ្ចឹងគាត់បានជិះតាក់ស៊ី
ហើយបានប្រាប់តាក់ស៊ីឲ្យទៅព្រលានយន្តហោះ
អញ្ចឹងបានន័យថាគាត់បញ្ចប់វិស្សមកាលរបស់គាត់នៅឯមាត់សមុទ្រ បន្ទាប់មកគាត់ត្រូវដល់ពេល
ត្រលប់ទៅស្រុកកំណើតរបស់គាត់វិញ ឬក៏ត្រលប់ទៅផ្ទះរបស់គាត់វិញ
ដូច្នេះគាត់បានជិះតាក់ស៊ីមួយគ្រឿង ដែលយើងឃើញតាក់ស៊ីនោះគឺមានពណ៌ផ្កាឈូក
ហើយយើងឃើញពណ៌ផ្កាឈូក ដែលយើងឃើញតាក់ស៊ីនោះ គឺមានកង់ចំនួនបួន
ដោយសារតែតាក់ស៊ីគឺជាឡាន អញ្ចឹងមានកង់ចំនួនបួន ប៉ុន្តែយើងមើលពីចំហៀង
[យើងឃើញ]កង់តែពីរទេ ហើយឡានគឺមានចង្កៀងស្តុប ឬក៏ស្តុប នៅខាងមុខពីរនិងខាងក្រោយពីរ
សម្រាប់បំភ្លឺផ្លូវ អញ្ចឹងនៅពេលដែលយើងបើកបរពេលយប់ យើងអាចបើកភ្លើងបាន

Copyright © 2016 www.aakanee.com – This document and the corresponding illustration and recording are provided under a Creative Commons Attribution-NonCommercial-ShareAlike 4.0 International License.

ហើយនៅពេលដែលយើងបើកបរពេលថ្ងៃ គឺយើងមិនបើក មិនចាំបាច់បើកភ្លើងនោះទេ
ដែលឡានគឺមានកញ្ចក់ពីរផងដែរ សម្រាប់មើលខាងក្រោយ គឺខាងឆ្វេងមួយ និងខាងស្តាំមួយ
ហើយយើងឃើញនៅលើដំបូលឡានតាក់ស៊ីនោះ គឺមានលើកជាដុំផ្លាកមួយ
ដែលដាក់ឈ្មោះថាតាក់ស៊ី អញ្ចឹងបានន័យថា នៅពេលដែលគាត់រត់តាក់ស៊ី
នៅពេលដែលអត់មានភ្ញៀវ គាត់អាចបើកភ្លើងនៅខាងលើដុំដំបូលនោះបាន នៅ
សម្រាប់ដុំលើដំបូលនោះបាន ប៉ុន្តែនៅពេលដែលមានភ្ញៀវ គឺគាត់បិទភ្លើងចេញ
អញ្ចឹងនៅពេលដែលគាត់បិទភ្លើង គឺគេអាចដឹងថាតាកស៊ីនោះមានមនុស្សជិះ អញ្ចឹងបុរសម្នាក់ហ្នឹង
គាត់អង្គុយខាងក្រោយ ហើយអ្នកបើកបរអង្គុយខាងមុខ
ដោយអ្នកបើកបរតាក់ស៊ីកំពុងតែសម្លឹងទៅខាងមុខ ហើយដៃរបស់គាត់កំពុងតែកាន់ចង្កូតឡាន
ដើម្បីបញ្ជារថយន្តទៅត្រង់ ចំណែកឯបុរសដែលគាត់មានវិស្សមកាលនៅមាត់សមុទ្រអម្បាញ់មិញ
គឺគាត់ពាក់វ៉ែនតាខ្មៅដដែល ហើយគាត់អង្គុយនៅខាងក្រោយ
ហើយគាត់បានប្រាប់ទៅអ្នកបើកបរតាក់ស៊ីថា គាត់ចង់ទៅព្រលានយន្តហោះ
អញ្ចឹងគាត់ចង់ទៅព្រលានយន្តហោះ ដោយសារតែគាត់ចប់វិស្សមកាលរបស់គាត់
ហើយគាត់ត្រូវត្រលប់ទៅផ្ទះរបស់គាត់វិញ។

បន្ទាប់មកទៀតរូបភាពទី ៣ នៅក្នុងរូបភាពទី ៣ យើងឃើញថា បន្តិចក្រោយមក
ក្រោយពីពួកគាត់បានជិះបន្តិចក្រោយមក ឡានតាក់ស៊ីមួយនោះ
ក៏គាត់បានមកដល់ព្រលានយន្តហោះ អញ្ចឹងនៅពេលដែលគាត់ចូលមកដល់ព្រលានយន្តហោះ
យើងឃើញគាត់បានជិះកាត់ខ្លោងទ្វារមួយ ដោយយើងឃើញគាត់ជិះកាត់ខ្លោងទ្វារមួយ
គឺជាខ្លោងទ្វារសម្រាប់អ្នកដំណើរដែលមកដល់ អញ្ចឹងខ្លោងទ្វារសម្រាប់អ្នកដំណើរដែលមកដល់
យើងឃើញមានរូបភាពនៅលើខ្លោងទ្វារនោះ នៅលើខ្លោងទ្វារនោះ
គឺយើងឃើញមានរូបភាពយន្តហោះកំពុងតែចុះ ដោយយើងឃើញ
អញ្ចឹងនៅពេលដែលយន្តហោះចុះ បានន័យថាអ្នកដំណើរមកដល់ ដូច្នេះបន្ទប់មួយនេះ
ឬក៏ខ្លោងទ្វារមួយនេះ គឺសម្រាប់ឲ្យយើងរង់ចាំអ្នកដំណើរ ឬក៏បងប្អូន
ឬក៏សាច់ញាតិដែលទើបតែមកពីក្រៅប្រទេស ឬក៏មកពីកន្លែងណាមួយដែលជិះយន្តហោះ
អញ្ចឹងនៅពេលដែលយើងទៅទទួលបងប្អូន ឬក៏ចាំបងប្អូន យើងត្រូវទៅកន្លែងអ្នកដំណើរមកដល់
ដូច្នេះនៅពេលដែលអ្នកដំណើរគាត់ចេញពីយន្តហោះ គាត់នឹងដើរកាត់មកច្រកនេះ
អញ្ចឹងយើងអាចចាំនៅខាងមុខច្រកនេះ ដើម្បីរង់ចាំទទួលពួកគាត់ ប៉ុន្តែដោយសារតែបុរសម្នាក់នោះ
គាត់ត្រូវឡើងយន្តហោះទៅស្រុកកំណើត ដូច្នេះគាត់អត់ឈប់នៅកន្លែងដែលយន្តហោះ
សម្រាប់អ្នកដំណើរមកដល់នោះទេ
អញ្ចឹងគាត់អត់ចាំបាច់ឈប់នៅកន្លែងមាត់ទ្វារអ្នកដំណើរមកដល់ទេ

Copyright © 2016 www.aakanee.com – This document and the corresponding illustration and recording are provided under a Creative Commons Attribution-NonCommercial-ShareAlike 4.0 International License.

គឺគាត់ឆ្លងកាត់ទៅកន្លែងអ្នកដំណើរចេញដំណើរ
អញ្ចឹងយើងឃើញនៅក្បែរខ្លោងទ្វារអ្នកដំណើរមកដល់ យើងឃើញមានរូបភាពយន្តហោះមួយទៀត
ដែលកំពុងតែឡើង ហោះឡើង អញ្ចឹងបានន័យថាកន្លែងនោះ គឺជាកន្លែង
សម្រាប់ដែលអ្នកដំណើរចេញដំណើរ ដូច្នេះគាត់បានជិះហួសកន្លែងដែលអ្នកដំណើរមកដល់
ដោយបន្តដំណើរទៅកាន់កន្លែងដែលយន្តហោះហោះឡើង។

បន្ទាប់មកទៀតរូបភាពទី ៤ នៅក្នុងរូបភាពទី ៤ គឺយើងឃើញថា
បន្ទាប់ពីគាត់មកដល់កន្លែងដែលអ្នកដំណើរត្រូវឡើងយន្តហោះហើយ
អញ្ចឹងគាត់បានមកដល់កន្លែងអ្នកដំណើរត្រូវឡើងយន្តហោះរួចរាល់ហើយ
ដូច្នេះគាត់ក៏បានយកវ៉ាលិស ដើម្បីឲ្យគេស្កេនមើល
អញ្ចឹងជាធម្មតានៅពេលដែលយើងចូលដល់ព្រលានយន្តហោះ គឺតែងតែមានកន្លែងសន្តិសុខមួយ
សម្រាប់ត្រួតពិនិត្យនូវសម្ភារះរបស់យើង ឬក៏កាតាប ឬក៏វ៉ាលិសរបស់យើង
ដែលពួកគាត់និងស្កេននិងត្រួតពិនិត្យដោយប្រព័ន្ធកុំព្យូទ័រ ដែលគាត់ប្រើប្រាស់ស្កេន
អញ្ចឹងគាត់ស្កេនមើលដើម្បីឲ្យដឹងថា តើនៅក្នុងវ៉ាលិស ឬក៏ក្នុងកាបូប
មានដាក់របស់គ្រោះថ្នាក់អ្វីដែរឬទេ ដោយសារតែការជិះយន្តហោះ គឺត្រូវប្រុងប្រយ័ត្ន
គឺមានការប្រុងប្រយ័ត្នខ្ពស់ ព្រោះថាការជិះយន្តហោះគឺវាមានគ្រោះថ្នាក់
ដូច្នេះគេមិនអនុញ្ញាតឲ្យយកវត្ថុគ្រោះថ្នាក់ផ្សេងៗទៅតាមខ្លួននោះទេ
អញ្ចឹងហើយនៅពេលដែលយើងចូលទៅដល់ព្រលានយន្តហោះ យើងត្រូវប្រគល់សម្ភារះរបស់យើង
ដូចជាកាតាប ដូចជាវ៉ាលិសធំៗហ្នឹង ដាក់ទៅលើកន្លែងស្កេន ឬក៏កន្លែងត្រួតពិនិត្យរបស់សន្តិសុខ
ដើម្បីឲ្យពួកគាត់ពិនិត្យថា តើកាតាបឬក៏វ៉ាលិសរបស់យើង មានវត្ថុដែលនាំអាចឲ្យមានគ្រោះថ្នាក់
ឬក៏អាចបង្កឲ្យមានគ្រោះថ្នាក់ដែរឬទេ អញ្ចឹងប្រសិនបើមាន គេនឹងឃាត់ទុក
គេនឹងអត់ឲ្យវ៉ាលិសរបស់យើងមកវិញនោះទេ ប៉ុន្តែប្រសិនបើអត់មានទេ
គេអាចអនុញ្ញាតឲ្យយើងយកទៅបាន អញ្ចឹងបុរសម្នាក់ហ្នឹង គាត់កំពុងតែដាក់វ៉ាលិសរបស់គាត់
ដែលមានពណ៌ផ្កាឈូក ឬក៏មានពណ៌ទឹកក្រូចហ្នឹង ដាក់ចូលទៅក្នុងម៉ាស៊ីនស្កេនរបស់សន្តិសុខ
ហើយយើងឃើញសន្តិសុខគាត់កំពុងតែអង្គុយមើលក្នុងកុំព្យូទ័ររបស់គាត់
ថាតើមានសម្ភារះអ្វីខ្លះនៅក្នុងវ៉ាលិសរបស់គាត់ ដោយយើងឃើញសន្តិសុខ
គាត់ស្លៀកពាក់ឯកសណ្ឋាន ជាអ្នកត្រួតពិនិត្យ ហើយគាត់មានពាក់មួកមួយផងដែរ
ដែលពាក់មួកមួយនោះ គឺមួកស្រដៀងទៅនឹងមួកប៉ូលិស ដោយគាត់អង្គុយទៅមើល
ដោយគាត់អង្គុយមើលកុំព្យូទ័រ ដែលនៅជាប់ម៉ាស៊ីនស្កេននោះ ដើម្បីឲ្យដឹងថា
តើវ៉ាលិសរបស់អ្នកដំណើរមានវត្ថុ ដែលមានគ្រោះថ្នាក់ដែរឬទេ។

Copyright © 2016 www.aakanee.com – This document and the corresponding illustration and recording are provided under a Creative Commons Attribution-NonCommercial-ShareAlike 4.0 International License.

បន្ទាប់មកទៀតរូបភាពទី ៥ នៅក្នុងរូបភាពទី ៥
យើងឃើញបន្ទាប់ពីគាត់ត្រួតពិនិត្យវ៉ាលិសរបស់គាត់ហើយ
បានន័យថាវ៉ាលិសរបស់គាត់ហ្នឹងគឺអត់មានវត្ថុដែលមានគ្រោះថ្នាក់ទេ ដូច្នេះសន្តិសុខ
ឬក៏អ្នកត្រួតពិនិត្យ គាត់អនុញ្ញាតឲ្យបុរសម្នាក់ហ្នឹង គាត់បន្តដំណើរមកខាងមុខទៀតបាន
ដូច្នេះបុរសម្នាក់នោះ គាត់ក៏បានបន្តដំណើរ ដើម្បីមកតម្រង់ជួរក្នុងការឆែកសំបុត្រ
អញ្ចឹងនៅពេលដែលយើងជិះយន្តហោះ យើងត្រូវការឆែកសំបុត្រម្តងទៀតសិន
មុននឹងយើងអាចទៅបន្តដំណើរទៅខាងមុខបាន ដូច្នេះនៅពេលដែលយើងត្រួតពិនិត្យវ៉ាលិសហើយ
យើងត្រូវមកតម្រង់ជួរដើម្បីឆែកសំបុត្រ អញ្ចឹងជាក់ស្តែងនៅក្នុងរូបភាពទី ៥ នេះ បុរសម្នាក់នោះ
គាត់ក៏បានចូលមកតម្រង់ជួរនៅក្នុងកន្លែងឆែកសំបុត្រ ដោយសារតែដើម្បីរក្សាសណ្តាប់ធ្នាប់
ដូច្នេះយើងអត់អាចចូលទៅមុន ឬក៏បញ្ជៀតគ្នានោះទេ អញ្ចឹងអ្នកណាមកមុន
អ្នកនោះអាចឆែកបានមុន ព្រោះមានមនុស្សច្រើន អញ្ចឹងមានមនុស្សច្រើន
ដូច្នេះដើម្បីរក្សាសណ្តាប់ធ្នាប់យើងត្រូវតម្រង់ជួរគ្នា ដែលជាក់ស្តែងនៅក្នុងរូបភាពទី ៥
យើងឃើញមានមនុស្សជាច្រើន មានប្រុស មានស្រី មានក្មេង
កំពុងតែឈរតម្រង់ជួរដើម្បីឆែកសំបុត្រ ដោយយើងឃើញទី ១ គឺមាននារីម្នាក់
ដែលគាត់កំពុងតែឆែកសំបុត្រ ហើយបន្ទាប់មកគឺមានបុរសម្នាក់ទៀត គាត់យួរវ៉ាលិស គាត់ពាក់អាវធំ
អញ្ចឹងគាត់ពាក់អាវធំជារបៀបអ្នកធ្វើការ ហើយគាត់យួរវ៉ាលិសមួយ ប៉ុន្តែបុរសម្នាក់នោះ
គឺមានក្បាលទំពែក អញ្ចឹងគាត់មានទំពែកសក់ បានន័យថាសក់របស់គាត់អត់មានទេនៅខាងមុខ
មានតែនៅខាងក្រោយ អញ្ចឹងនៅពេលដែលសក់មានតែបន្តិច យើងហៅថាក្បាលទំពែក
ឬក៏សក់ទំពែក ដែលខាងក្រោយបុរសដែលអត់សូវមានសក់ហ្នឹង គឺយើងឃើញមាននារីម្នាក់ទៀត
គាត់កំពុងតែកាន់វ៉ាលិសដ៏ធំរបស់គាត់ ដោយគាត់ពាក់វ៉ែនតាផងដែរ អញ្ចឹងនារីម្នាក់ហ្នឹង
គាត់ស្លៀករ៉ូបពណ៌លឿង រ៉ូបពណ៌លឿង អញ្ចឹងបានន័យថារ៉ូបគឺខុសពីអាវ
ដោយសារតែអាវយើងត្រូវស្លៀកជាមួយសំពត់ ក៏ប៉ុន្តែរ៉ូបគឺវែងជាងអាវ
បានន័យថាយើងគ្រាន់តែពាក់វាមកគឺវាអាចលុបដល់ជង្គង់តែម្តង
អញ្ចឹងយើងអត់ចាំបាច់ស្លៀកសំពត់ថែមមួយទៀតទេ អញ្ចឹងនារីនៅក្នុងរូបភាពទី ៥ នេះ
គាត់កំពុងតែស្លៀករ៉ូបពណ៌លឿង ហើយកាន់វ៉ាលិសធំមួយ
នៅខាងក្រោយនារីដែលស្លៀករ៉ូបពណ៌លឿងនោះ គឺយើងឃើញមានបុរសវ័យក្មេងម្នាក់ទៀត
គាត់កំពុងតែឈរកាន់វ៉ាលិសរបស់គាត់ដែរ ហើយតម្រង់ជួរដើម្បីឆែកសំបុត្រ ឬក៏ដើម្បីឆែកសំបុត្រ
អញ្ចឹងបុរសដែលគាត់ទើបតែបញ្ចប់ការវិស្សមកាល គឺឈរនៅក្រោយគេ
ប៉ុន្តែដោយសារតែគាត់រង់ចាំយូរ អញ្ចឹងដើម្បីកុំឲ្យធុញ ព្រោះពេលខ្លះនៅពេលដែលយើងរង់ចាំយូរ
គឺវាធ្វើឲ្យយើងធុញ អញ្ចឹងបុរសម្នាក់ហ្នឹង ដើម្បីកុំឲ្យធុញ គាត់ក៏បានស្តាប់កាស
គាត់យកកាសពីក្នុងហោប៉ៅរបស់គាត់ ហើយយកដាក់ចូលទៅក្នុងត្រចៀក

Copyright © 2016 www.aakanee.com – This document and the corresponding illustration and recording are provided under a Creative Commons Attribution-NonCommercial-ShareAlike 4.0 International License.

ដើម្បីស្ដាប់បទចម្រៀងកំដរអារម្មណ៍ អញ្ចឹងដោយសារតែមនុស្សច្រើន នៅក្នុងការតម្រង់ជួរ ដូច្នេះគាត់ត្រូវចំណាយពេលយូរ ដើម្បីរង់ចាំនៅក្នុងជួរ អញ្ចឹងហើយដើម្បីកុំឲ្យគាត់អផ្សុក ឬក៏កុំឲ្យធុញ គាត់យកកាសដើម្បីស្ដាប់បទចម្រៀង ដោយយើងឃើញគាត់កំពុងតែកាន់វ៉ាលិសពណ៌ទឹកក្រូចរបស់គាត់ឈរតម្រង់ជួរ។

បន្ទាប់មកទៀតរូបភាពទី [១៦] នៅក្នុងរូបភាពទី [១៦] យើងឃើញ បន្ទាប់ពីគាត់[កំពុង] ឈររង់ចាំអស់រយៈពេលដល់យូរមក ដូច្នេះមនុស្សដែលនៅខាងមុខគាត់ ក៏បានឆេកអ៊ីនអស់ និងត្រួតពិនិត្យសំបុត្រអស់ហើយ ដូច្នេះក៏ដល់វេនបុរសម្នាក់ហ្នឹង អញ្ចឹងបុរសដែលទើបតែបញ្ចប់វិស្សមកាល គាត់ក៏មកដល់កន្លែងឆែកសំបុត្រ ដែលយើងឃើញនៅកន្លែងឆែកសំបុត្រ គឺមានមនុស្សម្នាក់ទៀត បុរសម្នាក់កំពុងតែឈរនៅទីនោះ អញ្ចឹងគាត់ពាក់ឯកសណ្ឋានជាអ្នកឆែកសំបុត្រ ហើយនៅខាងមុខគាត់ គឺមានកុំព្យូទ័រមួយ គាត់មានកុំព្យូទ័រមួយ អញ្ចឹងគាត់នៅក្នុងបញ្ជរឆែកសំបុត្រ ហើយគាត់បានតម្រូវឲ្យបុរសម្នាក់ហ្នឹង ដាក់ថ្លឹងវ៉ាលិសរបស់គាត់នៅលើជញ្ជីង អញ្ចឹងជាទូទៅការធ្វើដំណើរនៅតាមយន្តហោះ គឺយើងតែងតែមានការកំណត់នៃគីឡូ ឬក៏កំណត់នៃទម្ងន់សម្ភារៈដែលយកតាមខ្លួន ដែលគេអាចកំណត់ដូចជាវ៉ាលិសដែលធំៗ អញ្ចឹងវ៉ាលិសធំៗ គឺគេអត់អាចដាក់នៅតាមខ្លួនបានទេ គឺបានន័យថាគេទុកនៅកន្លែងគូទយន្តហោះ បានន័យថាយើងត្រូវ គ្រាន់តែថ្លឹងហើយ គេនឹងមានភ្នាក់ងារយកវ៉ាលិសរបស់យើងទៅទុកក្នុងយន្តហោះ ដូច្នេះវ៉ាលិសធំៗ គឺកន្លែងខ្លះ នៅពេលដែលយើងទៅជិតៗ ឬក៏ទៅទីឆ្ងាយ គឺគេអាចកំណត់ទម្ងន់របស់វ៉ាលិសរបស់យើង ដូចជាយន្តហោះខ្លះ ក្រុមហ៊ុនអាកាសចរណ៍ ឬក៏ក្រុមហ៊ុនយន្តហោះខ្លះ គេកំណត់វ៉ាលិសគឺត្រឹម ៣០ គីឡូក្រាម អញ្ចឹងប្រសិនបើយើងដាក់លើស ៣០ គីឡូក្រាម គឺគេអត់ឲ្យយើងដាក់ទៅទេ បានន័យថាពេលខ្លះគេអាចដាក់ឲ្យយើងដកអីវ៉ាន់របស់យើងចេញ ឬក៏ដកខោអាវរបស់យើងចេញខ្លះ ដើម្បីឲ្យនៅសល់ត្រឹម ៣០ គីឡូ ប៉ុន្តែពេលខ្លះទៀតគេពិន័យជាប្រាក់ ដោយគេអាចពិន័យជាប្រាក់យើងទៅតាមចំនួនទម្ងន់ដែលយើងបានលើស អញ្ចឹងនៅក្នុងរូបភាពនេះ គឺបុរសម្នាក់ហ្នឹង គាត់បានដាក់វ៉ាលិសធំរបស់គាត់ហ្នឹងទៅថ្លឹងជញ្ជីង ក៏ប៉ុន្តែវ៉ាលិសរបស់គាត់គឺទម្ងន់អត់ដល់ ៣០ គីឡូក្រាមទេ បានន័យថាយើងឃើញនៅក្នុងនេះ គឺទម្ងន់វ៉ាលិសរបស់គាត់គឺ ២៦ គីឡូក្រាម ដូច្នេះគាត់អត់បានតម្រូវ អ្នកត្រួតពិនិត្យហ្នឹង គាត់អត់តម្រូវឲ្យបុរសម្នាក់ហ្នឹង គាត់យកអីវ៉ាន់ ឬក៏យកខោអាវរបស់គាត់ចេញខ្លះពីក្នុងវ៉ាលិសទេ ហើយមួយទៀតសម្រាប់វ៉ាលិសដែលយើងយកតាមខ្លួន បានន័យថាពេលខ្លះយើងគ្រាន់តែមានកាតាបតូចៗសម្រាប់ដាក់សម្ភារៈ ដូច្នេះយើងអាចដាក់តាមខ្លួន ឬក៏យកជាប់ខ្លួនបានពេលឡើងយន្តហោះ អញ្ចឹងពេលខ្លះសម្ភារៈតូចៗ ក៏គេត្រូវថ្លឹងទម្ងន់ដែរ បានន័យថាវ៉ាលិសដែលអាច ឬក៏កាតាបដែលអាចយកតាមខ្លួនបាន

Copyright © 2016 www.aakanee.com – This document and the corresponding illustration and recording are provided under a Creative Commons Attribution-NonCommercial-ShareAlike 4.0 International License.

ពេលខ្លះគេកំណត់ទម្ងន់ត្រឹម ១០ គីឡូ ឬក៏ ៧ គីឡូជាដើម អញ្ចឹងនៅពេលដែលលើសចំនួន
គេឲ្យយើងដកចេញ ប៉ុន្តែប្រសិនបើ ពេលខ្លះគេអាចនឹងឲ្យយើងផាកពិន័យជាប្រាក់ជាដើម
ដូច្នេះមុននឹងយើងអាចឡើងយន្តហោះបាន យើងត្រូវតែថ្លឹងសម្ភារៈរបស់យើងជាមុនសិន
បន្ទាប់មកយើងត្រូវត្រួតពិនិត្យសំបុត្រ។

ដែលនៅក្នុងរូបភាពទី ៧ នៅក្នុងរូបភាពទី ៧ បុរសម្នាក់នោះ គាត់ក៏បាន
បន្ទាប់ពីគាត់ថ្លឹងវ៉ាលិសរបស់គាត់ហើយ គឺមានភ្នាក់ងារគេដឹកជញ្ជូនវ៉ាលិសត្រូវដាក់ទៅក្នុងយន្តហោះ
បន្ទាប់មកបុរសម្នាក់ហ្នឹង គាត់កំពុងតែឈរនិយាយជាមួយនឹងអ្នកឆែកសំបុត្រ អញ្ចឹងនៅពេល
មុនពេលដែលយើងអាចចូលទៅក្នុងជិះយន្តហោះបាន យើងត្រូវមកយកសំបុត្រយន្តហោះ
មកនៅកន្លែងបញ្ជរឆែកសំបុត្រសិន ដោយយើងបាន ពេលខ្លះនៅពេលដែលយើងជិះយន្តហោះ
គឺយើងទិញសំបុត្រយន្តហោះតាមរយៈក្រុមហ៊ុនអាកាសចរណ៍
ក៏ប៉ុន្តែនៅពេលដែលយើងទិញសំបុត្រនៅក្រុមហ៊ុនអាកាសចរណ៍
គឺយើងអត់ទាន់បានសំបុត្រជិះយន្តហោះទេ អញ្ចឹងគឺយើងត្រូវមកយកសំបុត្រនៅកន្លែង
នៅកន្លែងព្រលានយន្តហោះ ដូច្នេះនៅពេលដែលយើងមកដល់កន្លែងបញ្ជរឆែកសំបុត្រ
គឺយើងអាចបង្ហាញទិន្នន័យដែលយើងបានទិញសំបុត្រយន្តហោះពីក្រុមហ៊ុនទេសចរណ៍
ឬក៏ក្រុមហ៊ុនអាកាសចរណ៍ហើយបង្ហាញទៅអ្នកត្រួតពិនិត្យសំបុត្រ
ដូច្នេះគាត់នឹងអាចចេញសំបុត្រយន្តហោះឲ្យយើងបាន អញ្ចឹងនៅក្នុងរូបភាពនេះ
គឺអ្នកត្រួតពិនិត្យសំបុត្រ គាត់កំពុងតែសួរទៅកាន់បុរសនោះ ថាតើគាត់ត្រូវការកៅអីអង្គុយបែបណា
ព្រោះការជិះយន្តហោះ គឺជាទូទៅអ្នកលក់សំបុត្រ ឬក៏អ្នកឆែកសំបុត្រ
មុននឹងគេចេញសំបុត្រយន្តហោះឲ្យយើង គឺយើង គឺតែងតែសួរយើងថា
តើចង់អង្គុយកៅអីប្រភេទណា ឬក៏កន្លែងណា ព្រោះពេលខ្លះយន្តហោះខ្លះធំ គឺមានកន្លែងអង្គុយបី
បានន័យថាអង្គុយមាត់ផ្លូវ អង្គុយកណ្តាល ឬក៏អង្គុយជាប់មាត់បង្អួច ដូច្នេះនៅក្នុងរូបភាពនេះ
គាត់កំពុងតែសួរបុរសម្នាក់នោះ[ថាតើ]ចូលចិត្តអង្គុយកៅអីមាត់ផ្លូវ ឬក៏ជាប់បង្អួច
អញ្ចឹងប្រសិនបើយើងចង់អង្គុយមាត់បង្អួចដើម្បីមើលទេសភាព
យើងអាចប្រាប់ទៅអ្នកត្រួតពិនិត្យសំបុត្រថាយើងចង់អង្គុយជិតមាត់បង្អួច
ដូច្នេះគេនឹងរៀបចំកៅអីជិតមាត់បង្អួចឲ្យយើងអង្គុយ
ក៏ប៉ុន្តែបើសិនបើយើងអត់ចូលចិត្តអង្គុយចិត្តមាត់បង្អួច យើងប្រាប់ថាអង្គុយចិត្តផ្លូវ
នោះអ្នកត្រួតពិនិត្យសំបុត្រនឹងអាចឲ្យយើងអង្គុយនូវចិត្តផ្លូវបាន
ដូច្នេះនៅពេលដែលយើងចង់អង្គុយកៅអីមួយណា យើងគ្រាន់តែប្រាប់ទៅអ្នកលក់សំបុត្រ
គឺជាការស្រេច។

Copyright © 2016 www.aakanee.com – This document and the corresponding illustration and recording are provided under a Creative Commons Attribution-NonCommercial-ShareAlike 4.0 International License.

បន្ទាប់មកទៀតរូបភាពទី ៨ នៅក្នុងរូបភាពទី ៨ យើងឃើញ
បន្ទាប់ពីគាត់ជ្រើសរើសសំបុត្ររួចរាល់ហើយ អញ្ចឹងបន្ទាប់ពីគាត់ជ្រើសរើសសំបុត្ររួចរាល់ហើយ
គាត់ក៏បានទទួលសំបុត្រពីអ្នកឆែក ឬក៏ត្រួតពិនិត្យសំបុត្រនោះ អញ្ចឹងនៅក្នុងរូបភាពនេះ
យើងឃើញសំបុត្រយន្តហោះរបស់គាត់ គឺជាសំបុត្រមួយដែលទៅកាន់ប្រទេសស្វីស
អញ្ចឹងបានន័យថាគាត់កំពុងតែទៅកាន់ប្រទេស[ស្វីស] ដែលទៅកាន់ទីក្រុងស៊ូរិច
អញ្ចឹងជាធម្មតានៅក្នុងសំបុត្រយន្តហោះ គឺតែងតែប្រាប់អំពីគោលដៅដែលយើងត្រូវទៅ
ហើយនិងលេខកៅអីដែលយើងអង្គុយ ដោយសារតែកៅអីយន្តហោះគឺមានលេខ
អញ្ចឹងយើងអត់អាចអង្គុយផ្តេសផ្តាសបានទេ ដូច្នេះនៅពេលដែលយើងទទួលសំបុត្រយន្តហោះ
យើងត្រូវពិនិត្យមើលលេខសំបុត្ររបស់យើង ថាតើយើងត្រូវអង្គុយកៅអីលេខប៉ុន្មាន
ដូច្នេះនៅពេលដែលយើងឡើងទៅលើយន្តហោះ
យើងអាចបង្ហាញសំបុត្រទៅកាន់អ្នកបម្រើការនៅក្នុងយន្តហោះ
ដូច្នេះគេនឹងនាំយើងទៅកាន់កៅអីដែលយើងត្រូវអង្គុយ ដែលនៅក្នុងរូបភាពទី ៨
គឺគាត់បានទទួលសំបុត្ររបស់គាត់ដែលមានលេខកៅអី គឺលេខ ៣៧ A
ហើយទីក្រុងរបស់គាត់ដែលត្រូវទៅគឺទីក្រុងស៊ូរិចនៃប្រទេស[ស្វីស]។

បន្ទាប់មកទៀតរូបភាពទី ៩ នៅក្នុងរូបភាពទី ៩ យើងឃើញថា
បន្ទាប់ពីគាត់ទទួលបានសំបុត្រហើយ អញ្ចឹងគាត់ត្រូវទៅកន្លែងដែលត្រូវឡើងយន្តហោះ
អញ្ចឹងនៅពេលដែលគាត់ត្រូវទៅកន្លែងដែលត្រូវឡើងយន្តហោះ
គឺមុននឹងពេលដែលគាត់ចូលទៅកន្លែងនោះ
គឺត្រូវឆ្លងកាត់ការត្រួតពិនិត្យលើខ្លួនប្រាណរបស់គាត់សិន
ដូច្នេះអម្បាញ់មិញគឺគេត្រួតពិនិត្យទៅលើវ៉ាលិសរបស់គាត់
អញ្ចឹងនៅពេលដែលគេត្រួតពិនិត្យវ៉ាលិសរបស់គាត់ហើយ
គឺគេយកវ៉ាលិសរបស់គាត់ទៅទុកក្នុងយន្តហោះ ចំណែកឯគាត់វិញ
គឺគេត្រូវត្រួតពិនិត្យសម្ភារៈនៅលើខ្លួនប្រាណរបស់គាត់ ដើម្បីឲ្យច្បាស់ថា
គាត់មិនមានរបស់អ្វីដែលមានគ្រោះថ្នាក់ ដើម្បីដាក់នៅលើយន្តហោះទេ
អញ្ចឹងពេលយើងជិះយន្តហោះ គឺគេអត់អាចឲ្យយើងយកកាំបិត ឬក៏កន្ត្រៃ ឬក៏ឧបករណ៍មុតស្រួច
ឬក៏អាវុធផ្សេងៗតាមខ្លួនទេ អញ្ចឹងយើងអត់អាចយកឧបករណ៍
ដែលបង្កឲ្យមានគ្រោះថ្នាក់តាមខ្លួនទេ ដូច្នេះគេត្រូវពិនិត្យដោយប្រព័ន្ធ [scanner] ម្តងទៀត
អញ្ចឹងគេស្កេនសម្ភារៈរបស់គាត់ម្តងទៀត ដូច្នេះគាត់ត្រូវដោះខ្សែក្រវាត់ គាត់ត្រូវយកកាបូបលុយ
ទូរស័ព្ទរបស់គាត់ ហើយនិងកាសស្តាប់ចម្រៀងរបស់គាត់ដែលគាត់ស្តាប់អម្បាញ់មិញ
ដាក់ចូលទៅក្នុងប្រអប់មួយ អញ្ចឹងដាក់ចូលទៅក្នុងប្រអប់មួយ ហើយគេយកប្រអប់នោះ

Copyright © 2016 www.aakanee.com – This document and the corresponding illustration and recording are provided under a Creative Commons Attribution-NonCommercial-ShareAlike 4.0 International License.

ដាក់មកក្នុងម៉ាស៊ីនស្កេន ដើម្បីត្រួតពិនិត្យមើលថាតើមានរបស់គ្រោះថ្នាក់ដែរឬទេ អញ្ចឹងយើងឃើញនៅក្នុងរូបភាពទី ៩ គឺមាននារីម្នាក់ គាត់កំពុងតែអង្គុយដើម្បីត្រួតពិនិត្យ គាត់កំពុងតែអង្គុយសម្លឹងទៅមើលកុំព្យូទ័ររបស់គាត់ ថាតើអ្នកដំណើរមានរបស់គ្រោះថ្នាក់ដែរឬទេ នៅពេលដែលគាត់ដាក់តាមខ្លួនឡើងជិះយន្តហោះ។

បន្ទាប់មកទៀតរូបភាពទី ១០ នៅក្នុងរូបភាពទី ១០ យើងឃើញបន្ទាប់ពីគាត់ត្រួតពិនិត្យសម្ភារៈរបស់គាត់ដែលដាក់តាមខ្លួនរួចហើយ អញ្ចឹងគឺគាត់អត់មានសម្ភារៈអ្វីដែលមានគ្រោះថ្នាក់នៅពេលដែលគាត់ជិះយន្តហោះនោះទេ ដូច្នេះសន្តិសុខដែលត្រួតពិនិត្យសម្ភារៈ គាត់អាចអនុញ្ញាតឲ្យបុរសនោះបន្តដំណើរទៀតបាន អញ្ចឹងមុនពេលដែលយើងអាចឡើងជិះយន្តហោះបាន យើងត្រូវតែមកពិនិត្យប៉ាស្ព័រសិន ដោយសារតែបុរសម្នាក់ហ្នឹង គាត់ត្រូវចេញក្រៅប្រទេស ដូច្នេះដើម្បីចេញក្រៅប្រទេសបាន យើងត្រូវមានប៉ាស្ព័រ ឬក៏លិខិតឆ្លងដែន អញ្ចឹងភាសាខ្មែរ យើងហៅថា លិខិតឆ្លងដែន ដោយសារតែយើងឆ្លងប្រទេស ដូច្នេះយើងត្រូវតែមានលិខិតឆ្លងដែនមួយ ដើម្បីអនុញ្ញាតឲ្យយើងឆ្លងដែន ប្រសិនបើយើងឆ្លងប្រទេសមួយទៅកាន់ប្រទេសមួយ អត់មានលិខិតឆ្លងដែនទេ នោះយើងហៅថាការឆ្លងដែនខុសច្បាប់ ដូច្នេះប៉ូលិសអាចចាប់យើងបាន អញ្ចឹងដើម្បីឲ្យមានការឆ្លងដែនស្របច្បាប់ គឺយើងត្រូវតែមានលិខិតឆ្លងដែន និងមានទិដ្ឋាការ ដែលមានសុពលភាព អញ្ចឹងយើងត្រូវសុំទិដ្ឋាការដែលមានសុពលភាពពីអាជ្ញាធរសាធារណៈ ដើម្បីអាចធ្វើការឆ្លងដែនបាន ដូច្នេះនៅក្នុងព្រលានយន្តហោះ នៅពេលដែលយើង មុននឹងយើងឡើងជិះយន្តហោះ គឺគេនឹងធ្វើការត្រួតពិនិត្យនូវលិខិតឆ្លងដែនរបស់យើង ថាតើលិខិតឆ្លងដែនរបស់យើងគឺនូវសុពលភាពដែរឬទេ អញ្ចឹងយើងឃើញរូបភាពទី ១០ នេះ គឺបុរសម្នាក់នោះ គាត់បានហុចលិខិតឆ្លងដែនរបស់គាត់ រួមជាមួយនឹងសំបុត្រយន្តហោះ ទៅឲ្យបុគ្គលិកម្នាក់ដែលនៅក្នុងទូ ឬក៏នៅក្នុងបន្ទប់ត្រួតពិនិត្យ អញ្ចឹងបុគ្គលិកម្នាក់នោះ គាត់ស្លៀកពាក់ឯកសណ្ឋានជាអ្នកត្រួតពិនិត្យលិខិតឆ្លងដែន ដែលយើងឃើញគាត់ពាក់អាវធំពណ៌ប្រផេះ ហើយមានក្រវាត់កពណ៌លឿងផងដែរ អញ្ចឹងគាត់កំពុងតែឈរនៅក្នុងបន្ទប់មួយ ដែលយើងឃើញបន្ទប់នោះគឺជាបន្ទប់កញ្ចក់ អញ្ចឹងគាត់អាចមើលឃើញអ្នកដំណើរបាន ហើយនៅខាងក្រោយខ្នងរបស់គាត់ គឺមានកុំព្យូទ័រមួយគ្រឿង គឺមានកុំព្យូទ័រមួយគ្រឿង អញ្ចឹងគាត់ប្រើកុំព្យូទ័រដើម្បីត្រួតពិនិត្យលិខិតឆ្លងដែនថាតើលិខិតឆ្លងដែននោះ មានសុពលភាពដែរឬទេ។

បន្ទាប់មកទៀតរូបភាពទី ១១ នៅក្នុងរូបភាពទី ១១ យើងឃើញ បន្ទាប់ពីគាត់ត្រួតពិនិត្យសំបុត្រយន្តហោះហើយ និងលិខិតឆ្លងដែនរួចហើយ

Copyright © 2016 www.aakanee.com – This document and the corresponding illustration and recording are provided under a Creative Commons Attribution-NonCommercial-ShareAlike 4.0 International License.

ដូច្នេះអត់ទាន់ដល់ពេលដែលគាត់ត្រូវឡើងយន្តហោះទេ ដោយសារតែម៉ោងនៅសល់ នៅសល់ម៉ោង
អញ្ចឹងគាត់ក៏បានដើរចូលទៅក្នុងផ្សារ នៅក្នុងផ្សារដែលនៅក្នុងព្រលានយន្តហោះនោះ
ព្រោះជាទូទៅផ្សារដែលនៅក្នុងព្រលានយន្តហោះ គឺមានលក់នូវទំនិញថោកៗ ដែលអត់មានពន្ធ
ដោយសារតែវាអត់មានពន្ធ ដូច្នេះគឺទំនិញនោះទាំងអស់នោះថោកៗ
ដែលជាក់ស្តែងនៅក្នុងរូបភាពនេះ គឺយើងឃើញមានផ្លាកបញ្ចុះតម្លៃជាច្រើនទៅលើមុខទំនិញ
ដែលយើងឃើញគាត់កំពុងតែដើរមើលនៅក្នុងផ្សារដែលនៅក្នុងព្រលានយន្តហោះ
ហើយយើងឃើញនៅក្នុងផ្សារគឺមានលក់សម្ភារៈជាច្រើន នៅក្នុងផ្សារនោះគឺមានលក់សម្ភារៈជាច្រើន
ដូចជាស្រា ដូចជាទឹកអប់ ឬក៏នំផ្សេងៗដែលយើងអាចរកទិញបាន
ប៉ុន្តែយើងឃើញនៅក្រោយខ្នងរបស់គាត់ គឺមានទំនិញមួយចំនួន គឺបញ្ចុះតម្លៃជាពិសេសផងដែរ
អញ្ចឹងពេលខ្លះ ទំនិញខ្លះ នៅពេលដែលគេចង់ឲ្យលក់ដាច់ច្រើន
នៅពេលដែលគេចង់ឲ្យលក់ដាច់ច្រើន គេអាចធ្វើការបញ្ចុះតម្លៃផងដែរ
ដើម្បីឲ្យអតិថិជនគិតថាវាថោក អញ្ចឹងទំនិញដែលបញ្ចុះតម្លៃគឺថោក ដូច្នេះអតិថិជនចូលចិត្តទិញ
អញ្ចឹងនៅក្នុងរូបភាពនេះគឺគាត់កំពុងតែដើរផ្សារនៅក្នុងព្រលានយន្តហោះ
ដែលមានលក់ទំនិញថោកៗ ព្រោះតែទំនិញអត់មានបង់ពន្ធ ហើយមានទំនិញខ្លះ
គឺកំពុងតែបញ្ចុះតម្លៃផងដែរ អញ្ចឹងគេបញ្ចុះតម្លៃ ដើម្បីតម្លៃកាន់តែទាប
នោះឲ្យមានអតិថិជនទិញកាន់តែច្រើន។

បន្ទាប់មកទៀតរូបភាពទី ១២ រូបភាពទី ១២
គឺយើងនិយាយអំពីតារាងដែលសម្រាប់ឲ្យយន្តហោះចេញដំណើរ អញ្ចឹងមានតារាងមួយ
សម្រាប់ជើងយន្តហោះចេញដំណើរគ្រប់ជើងយន្តហោះទាំងអស់ ដែលយើងឃើញនៅក្នុងតារាងនេះ
គឺមានទង់ជាតិ មានទង់ជាតិរបស់ប្រទេសនីមួយៗ ហើយមានឈ្មោះទីក្រុង
ដែលយើងឃើញនៅលើគេ ទីក្រុងលើគេជាទីក្រុងស៊ូរិចរបស់ប្រទេស[ស្វីស]
អញ្ចឹងទីក្រុងស៊ូរិចនឹងចេញដំណើរនៅម៉ោង ១៣:៤៥ នាទី បានន័យថាម៉ោង ១ រសៀល ៤៥ នាទី
អញ្ចឹងយន្តហោះនឹងចេញដំណើរនៅម៉ោង ១:៤៥ នាទីរសៀល ចំណែកឯនៅទី ២
គឺជាទីក្រុងប៊ែរលីន ដែលយើង ភាសាខ្មែរយើងហៅថាទីក្រុងប៊ែកឡាំង
យើងហៅថាទីក្រុងប៊ែកឡាំងនៅប្រទេសអាល្លឺម៉ង់ អញ្ចឹងប្រទេសអាល្លឺម៉ង់គឺ
ទីក្រុងធំរបស់គេគឺទីក្រុងប៊ែកឡាំង ដែលគេនឹងត្រូវចេញដំណើរនៅម៉ោង ១:៥០
បានន័យថាយឺតជាងយន្តហោះដែលចេញដំណើរទៅទីក្រុងស៊ូរិច ប្រទេស[ស្វីស] ចំនួន ៥ នាទី
ហើយជើងហោះហើរដែលត្រូវទៅទីក្រុងប៊ែកឡាំងនៃប្រទេសអាល្លឺម៉ង់ គឺ
ក៏គេចេញដំណើរត្រឹមត្រូវផងដែរ បានន័យថាអត់មានយឺតយ៉ាវ ឬក៏អត់មានពន្យារពេលនោះទេ
អញ្ចឹងទីក្រុងស៊ូរិចនៃប្រទេស[ស្វីស] ជាមួយនឹងទីក្រុងប៊ែកឡាំងនៃប្រទេសអាល្លឺម៉ង់

Copyright © 2016 www.aakanee.com – This document and the corresponding illustration and recording are provided under a Creative Commons Attribution-NonCommercial-ShareAlike 4.0 International License.

គឺប្រទេសទាំងពីរ គឺនៅតំបន់អឺរ៉ុបដូចគ្នា អញ្ចឹងបានន័យថាជើងហោះហើររបស់គេ គឺនៅក្បែរៗគ្នា
បានន័យថាគេចេញដំណើរក្បែរៗគ្នា ដោយសារតែគេនៅតំបន់អឺរ៉ុបដូចគ្នា
ក៏ប៉ុន្តែនៅក្នុងតារាងជើងហោះហើរ ចុងក្រោយគេគឺជាប្រទេស ទីក្រុងប៉េជីង ប៉េជីង ឬក៏ប៉េកាំង
ដែលជាទីក្រុងរបស់ប្រទេសចិន អញ្ចឹងប្រទេសចិនគឺជាប្រទេសដ៏ធំមួយដែលនៅក្នុងតំបន់អាស៊ី
ដែលជាប្រទេសធំជាងគេ ឬក៏ធំមួយ នៅក្នុងតំបន់អាស៊ី
ដែលយើងឃើញជើងហោះហើររបស់ប្រទេសចិន គឺនៅម៉ោង ១:៥៥ នាទី ឬក៏ម៉ោង ១៣:៥៥ នាទី
ក៏ប៉ុន្តែជើងហោះហើររបស់ចិន គឺត្រូវបានពន្យារពេល
ប្រហែលជាដោយសារតែមានបញ្ហាអាកាសធាតុ ឬក៏ប្រហែលជាមានបញ្ហាយន្តហោះ
ដូច្នេះគេត្រូវពន្យារពេល ដើម្បីត្រួតពិនិត្យបញ្ហាបច្ចេកទេសជាមុនសិន មុននឹងការធ្វើដំណើរ
ព្រោះដើម្បីចៀសវាងនូវគ្រោះថ្នាក់ផ្សេងៗកើតឡើងនៅពេលធ្វើដំណើរ ដូច្នេះគេត្រូវប្រុងប្រយ័ត្ន
ដោយត្រួតពិនិត្យក្នុងការធ្វើ មុននឹងការហោះហើរ
ដូច្នេះជើងហោះហើរទៅទីក្រុងប៉េកាំងនៃប្រទេសចិន គឺត្រូវបានពន្យារពេល
ដោយសារកត្តាមួយចំនួន ដូចជាកត្តាអាកាសធាតុ ឬក៏បញ្ហាបច្ចេកទេសជាដើម។

បន្ទាប់មកទៀតរូបភាពទី ១៣ នៅក្នុងរូបភាពទី ១៣ យើងឃើញ បន្ទាប់មក បុរសម្នាក់នោះ
គាត់ក៏បានឡើងមកដល់យន្តហោះ អញ្ចឹងគាត់បានឡើងមកដល់យន្តហោះ
ហើយគាត់ក៏បានអង្គុយនូវកន្លែងកៅអីអង្គុយរបស់គាត់
ដោយសារតែគាត់បានឲ្យសំបុត្រយន្តហោះរបស់គាត់
ទៅកាន់បុគ្គលិកដែលបម្រើការនៅក្នុងយន្តហោះ ដូច្នេះគាត់ងាយស្រួលក្នុងការរកកៅអីរបស់គាត់
ព្រោះលេខកៅអីរបស់គាត់គឺបុគ្គលិកនៅក្នុងបម្រើការនៅក្នុងយន្តហោះ គឺគាត់ស្គាល់
ដូច្នេះគាត់នាំបុរសម្នាក់នោះមកអង្គុយនៅកៅអីរបស់គាត់ ដោយគាត់អង្គុយនៅកៅអីជាប់មាត់បង្អួច
អញ្ចឹងគាត់បានទិញកៅអីនៅជាប់មាត់បង្អួចដើម្បីអង្គុយ
អញ្ចឹងនៅពេលដែលគាត់អង្គុយនៅលើយន្តហោះ គាត់បានពាក់ខ្សែក្រវាត់សុវត្ថិភាព
ជាទូទៅនៅពេលដែលយើងជិះយន្តហោះ យើងត្រូវពាក់ខ្សែក្រវាត់សុវត្ថិភាព
រៀងរាល់ពេលធ្វើដំណើរ គឺទាំងពេលឡើងយន្តហោះ និងពេលដែលយន្តហោះចុះចត
គឺយើងត្រូវពាក់ខ្សែក្រវាត់សុវត្ថិភាពជានិច្ច ដើម្បីរក្សាសុវត្ថិភាពរបស់យើង
នៅពេលដែលយន្តហោះហោះឡើង និងនៅពេលដែលយន្តហោះហោះចុះ
ដូច្នេះយើងឃើញបុរសម្នាក់នេះ គឺគាត់កំពុងតែដាក់ខ្សែក្រវាត់សុវត្ថិភាពរបស់គាត់នៅជុំវិញចង្កេះ
ព្រោះដើម្បីគាត់ចង់រក្សាសុវត្ថិភាពរបស់គាត់
កុំឲ្យគាត់មានគ្រោះថ្នាក់នៅពេលដែលយន្តហោះឡើងលើ ឬក៏យន្តហោះចុះចត។

Copyright © 2016 www.aakanee.com – This document and the corresponding illustration and recording are provided under a Creative Commons Attribution-NonCommercial-ShareAlike 4.0 International License.

បន្ទាប់មកទៀតរូបភាពទី ១៤ នៅក្នុងរូបភាពទី ១៤
យើងឃើញយន្តហោះកំពុងតែហោះឡើងចេញពីព្រលានយន្តហោះ
ដោយសារតែទីក្រុងដែលគាត់មកទស្សនា គឺជាទីក្រុងមួយដែលមានទេសភាព ឬក៏អាកាសធាតុល្អ
ដូច្នេះយើងឃើញមានព្រះអាទិត្យកំពុងតែរះ និងមានផ្ទៃមេឃស្រឡះ
ហើយមានពពកសបន្តិចបន្តួចនៅលើមេឃ អញ្ចឹងគឺផ្ទៃមេឃស្រឡះ ដូច្នេះយន្តហោះហោះឡើង
ទៅកាន់ទីក្រុងស៊ូរិចនៃប្រទេស[ស្វីស]
ដោយយើងឃើញយន្តហោះគឺតែងតែរត់ហោះនៅតាមផ្លូវរបស់យន្តហោះ
ដូច្នេះនៅពេលដែលវារត់ដល់ល្បឿនកំណត់ វានឹងហោះឡើង ដោយយើងឃើញនៅក្នុងរូបភាពនេះ
គឺយន្តហោះកំពុងតែហោះឡើងទៅលើចេញពីព្រលានយន្តហោះ ដើម្បីឆ្ពោះទៅលើអាកាស
អញ្ចឹងយើងឃើញអមសងខាងផ្លូវយន្តហោះ យើងឃើញមានរុក្ខជាតិតូចធំជាច្រើន
ដោយសារតែថ្ងៃនេះគឺអាកាសធាតុស្រឡះល្អ ដូច្នេះគឺយើងអាចមើលឃើញរុក្ខជាតិពណ៌បៃតង
និងផ្ទៃមេឃស្រឡះ ហើយព្រះអាទិត្យបញ្ចេញរស្មី ឬក៏ពន្លឺមកលើផែនដីផងដែរ។

បន្ទាប់មកទៀតរូបភាពទី ១៥ នៅក្នុងរូបភាពទី ១៥ យើងឃើញថា
នៅពេលដែលយន្តហោះកំពុងតែធ្វើដំណើរ គឺតែងតែមានការបម្រើភេសជ្ជៈ ឬក៏ចំណីអាហារ
ឬក៏អាហារសម្រន់នៅលើយន្តហោះផងដែរ ដោយនៅក្នុងរូបភាពនេះ បុរសម្នាក់នោះ
គាត់បានយកទឹកក្រូច បានន័យថាគាត់ទទួលបានទឹកក្រូចពីអ្នកបម្រើនៅលើយន្តហោះ
ចំនួនមួយកំប៉ុង ហើយគេក៏បានមានកែវមួយសម្រាប់ឲ្យគាត់ផងដែរ អញ្ចឹងបុរសម្នាក់ហ្នឹង
នៅពេលដែលគាត់កំពុងតែជិះ គាត់បានចាក់ទឹកក្រូចចូលទៅក្នុងកែវដើម្បីញ៉ាំ ហើយគាត់ជិះបណ្តើរ
គាត់ដាក់កាសស្តាប់ត្រចៀកគាត់បណ្តើរ ដោយសារតែការធ្វើដំណើរតាមផ្លូវឆ្ងាយ
អញ្ចឹងដើម្បីកុំឲ្យធុញថប់ ឬក៏កុំឲ្យអផ្សុក គាត់បានស្តាប់ចម្រៀងបណ្តើរ
និងអង្គុយញ៉ាំទឹកក្រូចបណ្តើរ ដោយគាត់ស្តាប់ចម្រៀង ដើម្បីកុំឲ្យរំខាន[ដល់]អ្នកដទៃ
គឺគាត់ត្រូវការប្រើកាសស្តាប់ត្រចៀក អញ្ចឹងគាត់ប្រើកាសស្តាប់ត្រចៀក
ដើម្បីដាក់ចូលត្រចៀករបស់គាត់ អញ្ចឹងគាត់អត់ស្តាប់រំខានដល់អ្នកដទៃទេ
បានន័យថាចម្រៀងទាំងអស់គឺឮតែគាត់ម្នាក់ឯងតែប៉ុណ្ណោះ អញ្ចឹងនៅក្នុងរូបភាពនេះ
គឺគាត់បានទទួលទឹកក្រូចនៅពេលដែលអ្នកបម្រើយន្តហោះគាត់បានផ្តល់អាហារសម្រន់ដល់ភ្ញៀវ
ហើយគាត់អង្គុយស្តាប់កាស ដើម្បីកុំឲ្យគាត់អផ្សុក ឬក៏កុំឲ្យគាត់ធុញ
នៅពេលដែលគាត់ជិះយន្តហោះទៅកាន់ផ្ទះរបស់គាត់វិញ។

បន្ទាប់មកទៀតរូបភាពទី ១៦ រូបភាពទី ១៦ គឺយើងឃើញថា បន្ទាប់ពីគាត់ជិះអស់ជាច្រើនម៉ោងមក
យន្តហោះក៏បានមកដល់ទីក្រុងស៊ូរិចនៃប្រទេស[ស្វីស] ក៏ប៉ុន្តែខុសគ្នាអំពីប្រទេសអម្បាញ់មិញ

Copyright © 2016 www.aakanee.com – This document and the corresponding illustration and recording are provided under a Creative Commons Attribution-NonCommercial-ShareAlike 4.0 International License.

ដោយសារតែទីក្រុងស៊ូរិចនៃប្រទេសស្វ៊ីសគឺត្រជាក់
ដូច្នេះយើងឃើញព្រលានយន្តហោះគឺសុទ្ធតែទឹកកក បានន័យថានៅជុំវិញគឺមានភ្នំទឹកកកជាច្រើន
អញ្ចឹងគឺបានន័យថាខែរងានៅក្នុងប្រទេសស្វ៊ីស ដូច្នេះវាធ្វើឲ្យធ្លាក់ទឹកកក
ដែលយើងឃើញទេសភាពជុំវិញគឺយើងអត់ឃើញមានដើមឈើពណ៌បៃតងទេ
អញ្ចឹងអត់មានដើមឈើពណ៌បៃតងទេ នៅពេលដែលធ្លាក់ទឹកកក ដូច្នេះធម្មជាតិទាំងអស់គឺរុំព័ទ្ធ
ឬក៏គ្របទៅដោយផ្ទាំងទឹកកក បានន័យថាកម្ទេចទឹកកកដែលធ្លាក់មកពីលើ បានន័យថាត្រជាក់ពេក
ដូច្នេះវានឹងធ្វើឲ្យកកនូវទឹកផ្សេងៗ ឬក៏កម្ទេចកម្ទីផ្សេងៗ អញ្ចឹងយើងឃើញនៅទីនេះ
គឺសុទ្ធតែមានភ្នំដែលគ្របដណ្ដប់ទៅដោយទឹកកក
ហើយនិងទេសភាពនៅតាមសងខាងផ្លូវយន្តហោះ គឺក៏សុទ្ធតែទឹកកកដែរ
គឺអត់មានរុក្ខជាតិពណ៌បៃតងនោះទេ
អញ្ចឹងយន្តហោះក៏បានមកដល់ព្រលានយន្តហោះនៃប្រទេសស្វ៊ីសនៃទីក្រុងស៊ូរិច
អញ្ចឹងយន្តហោះក៏បានចុះចតមកក្រោម។

បន្ទាប់មកទៀតរូបភាពទី ១៧ រូបភាពទី ១៧ នៅពេលដែលយន្តហោះចុះចតហើយ បុរសម្នាក់នោះ
នៅពេលដែលគាត់ចេញពីយន្តហោះ អញ្ចឹងគាត់ក៏បានចាំ មកចាំយកវ៉ាលិសរបស់គាត់
ដោយគាត់ដាក់នៅក្នុងយន្តហោះ ដូច្នេះនៅពេលដែលយើងចុះពីយន្តហោះ
យើងអត់ចាំបាច់យកវ៉ាលិសរបស់យើង ឬក៏ចាំយកវ៉ាលិសរបស់យើងចេញពីយន្តហោះនោះទេ
យើងគ្រាន់តែមកកន្លែងត្រួតពិនិត្យសំបុត្រឲ្យគេត្រួតពិនិត្យលិខិតឆ្លងដែន
បន្ទាប់មកយើងទៅកន្លែងមួយទៀត ដើម្បីចាំយកវ៉ាលិសយើងតែម្ដង
ដោយមានភ្នាក់ងាររបស់បុគ្គលិកដែលបម្រើការនៅព្រលានយន្តហោះ
គេនឹងមានការដឹកជញ្ជូនវ៉ាលិសរបស់យើងចេញពីយន្តហោះ
ហើយយើងយកមកដាក់នៅលើម៉ាស៊ីនមួយ ជាម៉ាស៊ីនដែលវិលជុំវិញ
ដូច្នេះគេនឹងដាក់វ៉ាលិសរបស់អ្នកដំណើរទាំងអស់លើម៉ាស៊ីននោះ
ហើយឲ្យអ្នកដំណើរទាំងអស់ឈរក្បែរម៉ាស៊ីន នៅពេលដែលគេឃើញវ៉ាលិសរបស់ខ្លួនគេ
គេនឹងចាប់យកមិនខាន ដូច្នេះបុរសម្នាក់ហ្នឹង គាត់កំពុងតែឈរនៅក្បែរម៉ាស៊ីនវិល
ឬក៏ម៉ាស៊ីនសម្រាប់ដាក់វ៉ាលិស ដើម្បីឈររង់ចាំវ៉ាលិសពណ៌ទឹកក្រូចរបស់គាត់
អញ្ចឹងនៅពេលដែលគាត់អត់ឃើញវ៉ាលិសរបស់គាត់ គឺគាត់អត់យកផ្ដេសផ្ដាសនោះទេ
ព្រោះនៅពេលដែលគាត់យកផ្ដេសផ្ដាស វាអាចធ្វើឲ្យអ្នកដទៃបាត់បង់វ៉ាលិសបាន
ដូច្នេះគាត់រង់ចាំតែវ៉ាលិសរបស់គាត់តែប៉ុណ្ណោះ ដោយវ៉ាលិសរបស់គាត់គឺមានពណ៌ទឹកក្រូច
ដូច្នេះគាត់អត់យកវ៉ាលិសដែលពណ៌ស ឬក៏ពណ៌ប្រផេះដែលរត់កាត់គាត់នោះទេ
អញ្ចឹងគាត់ឈររង់ចាំរហូតដល់វ៉ាលិសទឹកក្រូចរបស់គាត់មកដល់ អញ្ចឹងបុរសម្នាក់ហ្នឹង

Copyright © 2016 www.aakanee.com – This document and the corresponding illustration and recording are provided under a Creative Commons Attribution-NonCommercial-ShareAlike 4.0 International License.

គាត់ស្លៀកខោសជើងវែង ពាក់អាវខៀវដៃខ្លី ហើយគាត់ឈរជ្រែងហោប៉ៅ ដោយដាក់ដៃរបស់គាត់ចូលទៅក្នុងហោប៉ៅខោរបស់គាត់ ដែលគាត់ឈររង់ចាំវ៉ាលិសរបស់គាត់មកដល់ ដូច្នេះនៅពេលដែលវ៉ាលិសគាត់មកដល់ គាត់នឹងយកវ៉ាលិសរបស់គាត់ ហើយចេញពីព្រលានយន្តហោះ ដើម្បីទៅផ្ទះរបស់គាត់វិញ បន្ទាប់ពីគាត់ធ្វើការវិស្សមកាល ឬក៏ឈប់សម្រាកលំហែនៅក្នុងមាត់សមុទ្រ ដូច្នេះនៅពេលដែលគាត់បញ្ចប់វិស្សមកាលរបស់គាត់ គាត់ក៏បានធ្វើដំណើរតាមយន្តហោះមកកាន់ទីក្រុងស៊ូរិចនៃប្រទេសស្វ៊ីសវិញ។

Copyright © 2016 www.aakanee.com – This document and the corresponding illustration and recording are provided under a Creative Commons Attribution-NonCommercial-ShareAlike 4.0 International License.